**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ..................... សហវ. ...........

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ ...... ឆ្នាំ២០១៤

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ:** ករណីសំណើសុំពិនិត្យសម្រេចស្តីពីការចំណាយថវិកាកម្មវិធីក្រោមទឹកប្រាក់២០លានរៀល ដោយប្រើវិធីសាស្ត្រស្ទង់តម្លៃ ដែលបណ្តាឆ្នាំកន្លងមកអនុវត្តដោយផ្ទាល់នៅអង្គភាពសាមីនីមួយៗដោយមិនឆ្លងអង្គភាពលទ្ធកម្មសម្រាប់ការទិញការជួសជុលឬសេវាផ្សេងៗ។

**យោង:**
- លិខិតលេខ ៥៥៦៤ អយក.គលេ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំនូវយន្តការនិងនីតិវិធីសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈចំពោះថវិកាកម្មវិធី។ ដើម្បីសម្រួលដល់ការអនុវត្តថវិកាកម្មវិធីរបស់អង្គភាពនីមួយៗនៃក្រសួងអប់រំ យុវជន និងកីឡាអាចប្រព្រឹត្តទៅបានរលូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឯកភាពឱ្យក្រសួងអប់រំ យុវជន និងកីឡា បន្តអនុវត្តតាមខ្លឹមសារប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ដោយអនុញ្ញាតឱ្យអង្គភាពនីមួយៗនៃក្រសួងអប់រំ យុវជន និងកីឡា ចំណាយថវិកាដែលពាក់ព័ន្ធទៅនឹងការទិញ ការជួសជុល ឬសេវាផ្សេងៗ ដែលមានទឹកប្រាក់ក្រោម២០លានរៀល ត្រូវអនុវត្តតាមលំនាំនីតិវិធីនៃវិធីសាស្ត្រលទ្ធកម្ម "ស្ទង់តម្លៃ" រហូតដល់ពេលមានយន្តការនិងនីតិវិធីសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈចំពោះអង្គភាពថវិកាត្រូវបានរៀបចំរួចនិងប្រកាសដាក់ឱ្យអនុវត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តតាមការគួរ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ផ្ទះលេខ ៩២ ... រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

លេខ ៤៥ អយក.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងត្រូវបញ្ជូនទៅ

គ្រប់អង្គភាពក្រោមឱវាទក្រសួង និងរាជធានី ខេត្ត

" ដើម្បីអនុវត្ត "

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥

តបរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

អគ្គនាយក ៥

ចោច ម៉ុរ៉ាត់